៦ កក្កដា ២០១៦

# សេចក្តីប្រកាសទទួលយកសំណើសុំជំនួយខ្នាតតូច សម្រាប់តំបន់ហតស្ពតឥណ្ឌូភូមា

ប្រទេស៖ កម្ពុជា ចិន ឡាវ មីយ៉ាន់ម៉ា ថៃឡង់ដ៏ និងវៀតណាម
កាលបរិច្ឆេទឈប់ទទួល៖ ថ្ងៃពុធ ទី១៧ ខែសីហា ឆ្នាំ២០១៦
ទិសដៅយុទ្ធសាស្រ្ត៖ ៤ ឬ ៨ (លោក លោកស្រីអាចជ្រើសរើសទិសដៅយុទ្ធសាស្រ្តបានតែមួយគត់)

សូមផ្ញើសំណើសុំជំនួយខ្នាតតូចដែលមានថវិកាតិចជាង ឬត្រឹម ២០.០០០ ដុល្លារសហរដ្ឋអាមេរិក មកកាន់អាសយដ្ឋានអ៊ីម៉ែល CEPF-Indoburma@iucn.org

មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែង ត្រូវបានបង្កើតឡើងក្នុងគោលបំណងដើម្បីការពារតំបន់ដែលរងការគំរាមកំហែង និងសំបូរទៅដោយធនធានជីវចម្រុះច្រើនបំផុត នៅលើភពផែនដី (Biodiversity hotspots)។ មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែងនេះ គឺជាកិច្ចផ្តួចផ្តើមរួមមួយ រវាងទីភ្នាក់ងារអភិវឌ្ឍន៍បារាំង អង្គការអភិរក្សអន្តរជាតិ សហភាពអឺរ៉ុប មូលនិធិបរិស្ថានពិភពលោក រដ្ឋាភិបាលជប៉ុន មូលនិធិ John D. និង Catherine T. MacArthur និងធនាគារពិភពលោក ហើយក្នុងតំបន់ហតស្ពតឥណ្ឌូ-ភូមា ក៏ត្រូវបានគាំទ្រដោយមូលនិធិ Margaret A. Cargill ផងដែរ។ ទិសដៅសំខាន់ គឺដើម្បីធានាថាសង្គមស៊ីវិលមានការចូលរួមក្នុងកិច្ចការអភិរក្សជីវចម្រុះ។

តំបន់ហតស្ពតឥណ្ឌូ-ភូមា រួមមានតំបន់ទាំងអស់ដែលមិនមែនជាតំបន់សមុទ្រនៃប្រទេសកម្ពុជា សាធារណរដ្ឋប្រជាមានិតឡាវ មីយ៉ាន់ម៉ា ថៃឡង់ដ៏ និងវៀតណាម ព្រមទាំងតំបន់មួយចំនួននៃប្រទេសចិនភាគខាងត្បូង។

អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) កសិដ្ឋាន និងសួនរុក្ខកម្មខាឌូរី និងមូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែង (CEPF) សូមប្រកាសទទួលយកសំណើសុំជំនួយខ្នាតតូចសង្ខេបពីបណ្តាអង្គការមិនមែនរដ្ឋាភិបាល ក្រុមសហគមន៍ ក្រុមហ៊ុនឯកជន និងអង្គការសង្គមស៊ីវិលផ្សេងៗទៀត ចំពោះគម្រោងអភិរក្សជីវចម្រុះ ក្នុងបណ្តាប្រទេសទាំងអស់នេះនៃតំបន់ហតស្ពតឥណ្ឌូ-ភូមា។

រាល់អ្នកលើកសំណើសុំជំនួយទាំងអស់ សូមអាន និងស្វែងយល់ឲ្យស៊ីជម្រៅពីយុទ្ធសាស្រ្តវិនិយោគរបស់ **មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែង** ដែលមានសង្ខេបជាភាសាខ្មែរ សូមចុចត្រង់នេះ និងមានឯកសារលម្អិតជាភាសាអង់គ្លេស សូមចុចត្រង់នេះ (ឯកសារនេះមានទម្រង់ជា PDF ទំហំ 8.6MB) និងសូមទំនាក់ទំនងមកកាន់ក្រុមការងារគ្រប់គ្រងមូលនិធិថ្នាក់តំបន់ ឥណ្ឌូ ភូមា តាមរយៈអ៊ីម៉ែល៖ CEPF-Indoburma@iucn.org) ប្រសិនបើមានចម្ងល់ ឬសំណួរ។

សូមបញ្ជាក់ថា មូលនិធិនឹងត្រូវផ្តល់ជូនចំពោះសំណើសុំជំនួយទាំងឡាយណា ដែលឆ្លើយតបចំបំផុតទៅនឹងយុទ្ធសាស្រ្តវិនិយោគនៃមូលនិធិ CEPF នេះ។ អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ កសិដ្ឋាន និងសួនរុក្ខកម្មខាឌូរី និងមូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែង សូមស្វាគមន៍ទទួលយក

សំណើសុំជំនួយពីបណ្តាដៃគូទទួលជំនួយនានាដែលធ្លាប់ទទួលបានកាលពីដំណាក់កាលមុនៗ ព្រមទាំងអង្គការនានាដែលពីមុនមិនទាន់ទទួលបានការផ្តល់មូលនិធិពី CEPF នៅឡើយ។

អង្គការសង្គមស៊ីវិលក្នុងស្រុក និងអន្តរជាតិ មានលក្ខណៈគ្រប់គ្រាន់ក្នុងការដាក់សំណើសុំជំនួយនេះ។ សូមបញ្ជាក់ថា នឹងមានការផ្តល់ជូនចំពោះគម្រោងណាដែលបង្ហាញតួនាទីឈានមុខគេសម្រាប់អង្គការក្នុងស្រុក និងមានការផ្តោតជាក់លាក់លើការកសាងសមត្ថភាពសម្រាប់អង្គការសង្គមស៊ីវិលថ្នាក់មូលដ្ឋាន។

**ទិសដៅយុទ្ធសាស្ត្រចំនួន ២ ដែលនឹងត្រូវទទួលបានការផ្តល់មូលនិធិលើកនេះ៖**

**ទិសដៅយុទ្ធសាស្ត្រទី៤៖ ផ្តល់សិទ្ធិអំណាចដល់សហគមន៍មូលដ្ឋានក្នុងការចូលរួមការពារ និងគ្រប់គ្រងតំបន់ជីវចម្រុះសំខាន់ៗអាទិភាព**

***សូមកត់សម្គាល់ថា៖*** *រាល់គម្រោងក្រោមទិសដៅយុទ្ធសាស្ត្រនេះ ៤.១ ៤.២ និង៤.៣ ត្រូវតែផ្តោតលើតំបន់អាទិភាពមួយ ឬច្រើនជាងមួយ ដូចដែលបានបង្ហាញក្នុងតារាង២៤ លើទំព័រទី ១៩៨ ក្នុងឯកសារស្តីពី លក្ខណៈនៃប្រព័ន្ធអេកូឡូស៊ី។ ប្រសិនបើ មានចង្ងល់ សូមទាក់ទងមកកាន់ក្រុមការងារគ្រប់គ្រងមូលនិធិថ្នាក់តំបន់។*

អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) កសិដ្ឋាន និងសួនរុក្ខកម្មខាឌូរី និងមូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែង (CEPF) សូមប្រកាសទទួលយកសំណើសុំជំនួយនានាដែលដោះស្រាយការវិនិយោគអាទិភាពមួយ ឬច្រើន ដូចខាងក្រោម៖

៤.១ លើកកម្ពស់ការយល់ដឹងអំពីច្បាប់អភិរក្សជីវចម្រុះ ក្នុងចំណោមក្រុមគោលដៅ នៅតាមតំបន់អាទិភាព

៤.២ សាកល្បង និងបង្កើនសហគមន៍ព្រៃឈើ សហគមន៍នេសាទ និងសហគមន៍តំបន់ការពារធម្មជាតិ

៤.៣ បង្កើតយន្តការនៃការគ្រប់គ្រងរួមសម្រាប់តំបន់ការពារនានា ដែលជម្រុញឲ្យមានការចូលរួមពីសហគមន៍នៅគ្រប់កម្រិតទាំងអស់នៃការគ្រប់គ្រង និងអភិបាលកិច្ច

**ទិសដៅយុទ្ធសាស្ត្រទី៨៖ ពង្រឹងសមត្ថភាពអង្គការសង្គមស៊ីវិលដើម្បីបំពេញការងារទៅលើបញ្ហាជីវចម្រុះ សហគមន៍ និងជីវភាពរស់នៅ នៅថ្នាក់តំបន់ ជាតិ ក្រោមជាតិ និងមូលដ្ឋាន**

***សូមគត់សម្គាល់ថា៖*** *អាទិភាពផ្តល់ជូនចំពោះគម្រោងណាក្រោមអាទិភាពវិនិយោគ ៨.១ ដែលបង្កើតឲ្យមានអង្គភាពសម្របសម្រួលដែលមានធនធានគ្រប់គ្រាន់និងមានអណត្តិច្បាស់លាស់ និងបង្កើតទំនាក់ទំនងរវាងវិស័យនានា ដើម្បីលើកកម្ពស់អភិបាលកិច្ចល្អ*

អង្គការសហភាពអន្តរជាតិដើម្បីការអភិរក្សធម្មជាតិ (IUCN) កសិដ្ឋាន និងសួនរុក្ខកម្មខាឌូរី និងមូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែង (CEPF) សូមប្រកាសទទួលយកសំណើសុំជំនួយនានាដែលដោះស្រាយការវិនិយោគអាទិភាពមួយ ឬច្រើន ដូចខាងក្រោម៖

៨.១ គាំទ្រដល់សកម្មភាពដែលមានលក្ខណៈជាបណ្តាញ ដែលជម្រុញឲ្យមានការឆ្លើយតបរបស់អង្គការសង្គមស៊ីវិលចំពោះការគំរាមកំហែងអាទិភាព និងកំពុងលេចឡើង

៨.២ ផ្តល់នូវការគាំទ្រស្នូលចំពោះការរៀបចំបង្កើតអង្គការសង្គមស៊ីវិលក្នុងស្រុក

៨.៣ បង្កើតយន្តការថ្នាក់កណ្តាលដើម្បីផ្សារភ្ជាប់ក្រុមអ្នកស្ម័គ្រចិត្តទៅនឹងតម្រូវការបំពាក់បំប៉នរបស់អង្គការសង្គមស៊ីវិល

**ព័ត៌មានបន្ថែម**

រាល់បុគ្គលម្នាក់ៗត្រូវបានលើកទឹកចិត្តឲ្យមានការសហការជាមួយអង្គការសង្គមស៊ីវិលដើម្បីសរសេរលើកសំណើសុំជំនួយនេះ ជាជាងការស្នើសុំជាលក្ខណៈបុគ្គល។

ប្រសិនបើលោក លោកស្រីមានចង្ងល់អំពីលក្ខណៈវិនិច្ឆ័យក្នុងការដាក់សំណើសុំជំនួយនេះ សូមទំនាក់ទំនងមកកាន់ក្រុមការងារគ្រប់គ្រងមូលធិនិថ្នាក់តំបន់ តាមរយៈអ៊ីម៉ែល៖ CEPF-Indoburma@iucn.org។ មានគោលការណ៍ណែនាំសម្រាប់អ្នកលើកសំណើសុំជំនួយទាំងអស់ ហើយបណ្តាអង្គការសង្គមស៊ីវិលទាំងអស់ដែលមានបំណងដាក់សំណើសុំជំនួយនេះ ត្រូវបានលើកទឹកចិត្តឲ្យមានការទាក់ទងមកកាន់ក្រុមការងារគ្រប់គ្រងមូលធិនិថ្នាក់តំបន់ តាមរយៈអ៊ីម៉ែល៖ CEPF-Indoburma@iucn.org មុននឹងចាប់ផ្តើមសរសេរសំណើសុំជំនួយ។

ជំនួយដែលផ្តល់ឲ្យមិនអាចយកទៅប្រើប្រាស់សម្រាប់៖ (១) ទិញដី (២) សកម្មភាពរុះរើ ឬធ្វើឲ្យខូចដល់ទ្រព្យសម្បត្តិវប្បធម៌រូបវន្ត (ដែលមានដូចជា ទីតាំងដែលមានតម្លៃផ្នែកបុរាណវត្ថុវិទ្យា ផ្នែកបាសាណិកូតវិទ្យា ផ្នែកប្រវត្តិសាស្រ្ត សាសនា ឬក៏តម្លៃរបស់ធម្មជាតិដែលមានតែមួយ (៣) ផ្លាស់ប្តូរលំនៅដ្ឋានរបស់ប្រជាពលរដ្ឋ ឬក៏ការរុះរើតាំងទីលំនៅសារជាថ្មីដោយគ្មានការស្ម័គ្រចិត្ត (៤) ផ្គត់ផ្គង់បន្ថែមទៅលើមូលនិធិ (ត្រាស់ហ្វាន់)។ រាល់សកម្មភាពទាំងអស់ត្រូវគោរពតាមគោលនយោបាយការពារសង្គមនិងបរិស្ថានរបស់មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែង ដែលមានលើគេហទំព័រ សូមចុចត្រង់នេះ។

មូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែង(CEPF) គាំទ្រដល់សកម្មភាពអភិរក្សជីវចម្រុះ តាមរយៈការផ្តល់ជំនួយ ២ ប្រភេទ៖ ជំនួយខ្នាតធំដែលមានថវិកាចាប់ពី ២០.០០០ ដុល្លារសហរដ្ឋអាមេរិកឡើងទៅ និងជំនួយខ្នាតតូចដែលមានថវិកាត្រឹម ២០.០០០ ដុល្លារសហរដ្ឋអាមេរិក ឬតិចជាងនេះ។

អ្នកលើកសំណើសុំជំនួយខ្នាតតូច (ត្រឹម ២០.០០០ដុល្លារសហរដ្ឋអាមេរិក) អាចសរសេរជាភាសាអង់គ្លេស ឬភាសាខ្មែរក៏បាន ដោយប្រើគំរូសំណើសុំជំនួយ ដែលមាននៅលើ សូមចុចត្រង់នេះ។នៅពេលសំណើត្រូវបានរៀបចំរួច សូមផ្ញើអ៊ីម៉ែលមកកាន់ CEPF-Indoburma@iucn.org ដោយត្រូវភ្ជាប់មកជាមួយផងនូវសំណើសុំសង្ខេបដែលបានបំពេញរួចហើយនោះ។ លោក លោកស្រី នឹងទទួលបាននូវការជូនដំណឹងពីការទទួលបានសំណើ ។ លោក លោកស្រីនឹងត្រូវបានទាក់ទងពីជំហាន ដែលនឹងត្រូវធ្វើបន្ទាប់ទៀត ប្រសិនបើសំណើរបស់លោក លោកស្រី ជាប់នៅជំណាក់កាលទី១។ រាល់សំណួរ ឬចម្ងល់ក្នុងអំឡុងពេលនៃដំណើរការលើកសំណើសុំនេះ អាចសាកសួរបានតាមរយៈអ៊ីម៉ែល៖ CEPF-Indoburma@iucn.org ។

កាលបរិច្ឆេទឈប់ទទួលយកសំណើសុំជំនួយសង្ខេប នៅថ្ងៃពុធ ទី១៧ ខែសីហា ឆ្នាំ២០១៦។

**សូមកត់សម្គាល់ថា៖** ការដាក់សំណើសុំជំនួយសង្ខេបជាឯកសារបោះពុម្ពចេញ នឹងមិនត្រូវបានទទួលយកឡើយ។ ចំលើយចំពោះសំណួរដែលត្រូវបានសួរជាញឹកញាប់ (ជាភាសាអង់គ្លេស) សូមចុចត្រង់នេះ។

**<u>សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖</u>**

ក្រុមការងារគ្រប់គ្រងមូលនិធិថ្នាក់តំបន់នៃមូលនិធិភាពជាដៃគូសម្រាប់ប្រព័ន្ធអេកូឡូស៊ីដែលរងការគំរាមកំហែង

ការិយាល័យអង្គការ IUCN ប្រចាំតំបន់អាស៊ី

#៦៣ តំបន់សុខុមវីត ៣៩ វឌ្ឍថានា បាងកក ១០១១០ ថៃឡង់ដ៏

អ៊ីម៉ែល៖ CEPF-Indoburma@iucn.org

ទូរស័ព្ទ៖ +៦៦ ២ ៦៦២ ៤០២៩ ទូរសារ៖ +៦៦ ២ ៦៦២ ៤៣៨៩